**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បែបបទ និងលក្ខខណ្ឌ នៃការគ្រប់គ្រងអាស៊ីដខ្លាំង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១១/០២០ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង
- បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញអនុក្រឹត្យ លេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យ លេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីបែបបទ និងលក្ខខណ្ឌ នៃការលក់ ការទិញ ការរក្សាទុក ការចែកចាយ ការដឹកជញ្ជូន ការផលិត ការយកតាមខ្លួន និងការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅ កំណត់អំពីការគ្រប់គ្រងអាស៊ីដខ្លាំងគ្រប់ប្រភេទ តាមបទដ្ឋានបច្ចេកទេស ដើម្បីបង្ការទប់ស្កាត់ បង្ក្រាបបទល្មើស ដែលបង្កឡើងដោយការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើរាល់សកម្មភាពនៃការលក់ ការទិញ ការរក្សាទុក ការចែកចាយ ការដឹកជញ្ជូន ការផលិត ការយកតាមខ្លួននិងការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

អាស៊ីដខ្លាំងនៅក្នុងអនុក្រឹត្យនេះ សំដៅដល់អាស៊ីដ វត្ថុធាតុដើម និងធាតុផ្សំជាអាស៊ីដ ទោះជាល្បាយរាវ ឬ រឹង ហើយមានប៉េហាស់ (pH) ស្មើ ឬ ក្រោម ៣ (បី) ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និង

អាយុជីវិតមនុស្ស ដូចមានចុះនៅក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង លើកលែងអាស៊ីដស៊ុលហ្វួរិក ដែលជា ល្បាយរាវ (សូលុយស្យុង) និង មានកំហាប់ ឬ ដង់ស៊ីតេក្រោម ៣៣% ដែលប្រើប្រាស់សម្រាប់ចាក់អាគុយ ។

## ជំពូកទី២
## បែបបទ និងលក្ខខណ្ឌនៃការគ្រប់គ្រងអាស៊ីដខ្លាំង

**មាត្រា ៥.-**

ការលក់ ការទិញ ការរក្សាទុក ការចែកចាយ ការដឹកជញ្ជូន ការវេចខ្ចប់ ការយកតាមខ្លួន និងការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវគោរពតាមបទដ្ឋានបច្ចេកទេសនិងត្រូវអនុវត្តតាមបែបបទ និងលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី២ នៃអនុក្រឹត្យនេះ។

**មាត្រា ៦.-**

អ្នកលក់ ឬអ្នកចែកចាយអាស៊ីដខ្លាំងគ្រប់ប្រភេទត្រូវ ៖

- មានទីតាំងលក់ ឬ ចែកចាយអាស៊ីដខ្លាំងគ្រប់ប្រភេទ ដែលទទួលបានការអនុញ្ញាតពីអាជ្ញាធររដ្ឋបាលរាជធានី ខេត្ត ដោយមានការផ្តល់យោបល់បច្ចេកទេសពីស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- លក់ ឬ ចែកចាយជូនតែអតិថិជនណាដែលបង្ហាញឯកសារដូចមានចែងនៅក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ
- កត់ត្រារាល់ព័ត៌មានស្តីពីការទិញចូល ការលក់ចេញ ក្នុងសៀវភៅបញ្ជីការតាមគំរូ ដែលកំណត់ដោយអង្គភាពនគរបាលជំនាញ ងាយស្រួលពិនិត្យនៅពេលចាំបាច់ដោយសមត្ថកិច្ច
- រក្សាទុក វេចខ្ចប់អាស៊ីដខ្លាំង ដោយប្រកដប ឬ ធុងដែលធានាសុវត្ថិភាព មានគម្របបិទជិត មិនអាចបើកបាន ដោយងាយស្រួល និងត្រូវមានស្លាកសញ្ញាសំគាល់ប្រភេទអាស៊ីដ សញ្ញាព្រមានអំពីគ្រោះថ្នាក់
- ផ្តល់វិក្កយបត្រលក់អាស៊ីដខ្លាំងដល់អ្នកទិញ
- មានឯកសារបញ្ជាក់អំពីប្រភពដើមច្បាស់លាស់ និងមានតារាងព័ត៌មានសុវត្ថិភាព (Material Safety Data Sheet - MSDS)។

**មាត្រា ៧.-**

អ្នកទិញអាស៊ីដខ្លាំងគ្រប់ប្រភេទត្រូវ ៖

- មានអាយុចាប់ពី១៨ឆ្នាំឡើង
- បង្ហាញឯកសារដែលពាក់ព័ន្ធ ៖ អត្តសញ្ញាណប័ណ្ណ និងឬអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបញ្ជាក់ពីមុខរបរវិជ្ជាជីវៈ ដែលពាក់ព័ន្ធដល់ការប្រើប្រាស់អាស៊ីដខ្លាំង
- បញ្ជាក់អំពីគោលបំណងប្រើប្រាស់ជាក់លាក់ នៃការទិញអាស៊ីដខ្លាំង

- មានវិក្កយបត្រពីអ្នកលក់ ឬអ្នកចែកចាយ សម្រាប់បង្ហាញដល់សមត្ថកិច្ចនៅពេលយកតាមខ្លួន ឬពេលដឹកជញ្ជូន ឬពេលរក្សាទុកប្រើប្រាស់ ។

**មាត្រា ៨.-**

ឃ្លាំងរក្សាទុកអាស៊ីដខ្លាំងគ្រប់ប្រភេទសម្រាប់លក់ ឬ ចែកចាយ ត្រូវអនុវត្តតាមបែបបទ និងលក្ខខណ្ឌដូចខាងក្រោម៖

- ទីតាំងត្រូវស្ថិតនៅឆ្ងាយពីទីប្រជុំជន និងត្រូវមានការឯកភាពពីអាជ្ញាធរមានសមត្ថកិច្ច
- ត្រូវមានប្រព័ន្ធការពារសុវត្ថិភាព តាមលក្ខណៈបច្ចេកទេស
- ត្រូវមានប្រព័ន្ធបង្ការពន្លត់អគ្គិភ័យដោយមានការពិនិត្យបញ្ជាក់ពីអង្គភាពនគរបាលជំនាញ
- ត្រូវធ្វើកំណត់ត្រាពីបរិមាណ និងប្រភេទអាស៊ីដច្បាស់លាស់ និងត្រូវរក្សាទុកឯកសារដែលពាក់ព័ន្ធ ប្រភពដើម នៃអាស៊ីដ
- ត្រូវគោរពតាមបទដ្ឋានបច្ចេកទេស ស្តីពីការរក្សាទុកសារធាតុគីមីក្នុងឃ្លាំង ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៩.-**

ការដឹកជញ្ជូនអាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវអនុវត្តតាមបែបបទ និងលក្ខខណ្ឌ ដូចខាងក្រោម ៖

- មធ្យោបាយដឹកជញ្ជូនត្រូវធានាពីលក្ខណៈបច្ចេកទេសស្របតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនិងការកំណត់ដោយបទដ្ឋានគតិយុត្តផ្សេងទៀត
- ត្រូវដឹកជញ្ជូនតែអាស៊ីដខ្លាំងណា ដែលបានវេចខ្ចប់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដូចមានចែងនៅក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ និងត្រូវភ្ជាប់ជាមួយនូវឯកសារដែលពាក់ព័ន្ធ
- ការដឹកជញ្ជូនអាស៊ីដខ្លាំងគ្រប់ប្រភេទចាប់ពី ១.០០០គីឡូក្រាមឡើង មិនត្រូវឆ្លងកាត់ទីក្រុង ទីប្រជុំជន ឬលើដងផ្លូវដែលមានមនុស្សច្រើនកុះករ។ក្នុងករណីចាំបាច់ដែលត្រូវឆ្លងកាត់ត្រូវមានកម្លាំងសមត្ថកិច្ចជួយការពារ។

**មាត្រា ១០.-**

ការវេចខ្ចប់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវអនុវត្តតាមបែបបទ និងលក្ខខណ្ឌ ដូចខាងក្រោម ៖

- ត្រូវវេចខ្ចប់ដោយប្រកដប ឬធុងសុវត្ថិភាព ដែលធានាមិនហែក បែកធ្លុះធ្លាយ ធន់នឹងអាកាសធាតុ មានភាពជាប់មាំល្អ ដើម្បីធានាគុណភាព សុវត្ថិភាពក្នុងការរក្សាទុក ដឹកជញ្ជូន និងការប្រើប្រាស់
- ត្រូវមានស្លាកសញ្ញាសរសេរជាភាសាខ្មែរ ដែលងាយយល់ មានព័ត៌មានគ្រប់គ្រាន់ មិនងាយលុប ជាប់ល្អ និងបញ្ជាក់អំពីការព្រមានគ្រោះថ្នាក់ ដូចមានចែងក្នុងវិធានស្តីពីការវេចខ្ចប់សារធាតុគីមី ឬ វិធានដទៃទៀត ដែលមានជាធរមាន។

**មាត្រា ១១.-**

អ្នកយកអាស៊ីដខ្លាំងគ្រប់ប្រភេទតាមខ្លួន ត្រូវអនុវត្តតាមបែបបទ និងលក្ខខណ្ឌ ដូចខាងក្រោម៖

- ត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- ត្រូវវេចខ្ចប់ ឬប្រកទុកដាក់ឲ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព
- ត្រូវមានវិក្កយបត្រ ឬឯកសារបញ្ជាក់អំពីអាស៊ីដខ្លាំង ទុកបង្ហាញសមត្ថកិច្ចពេលមានការត្រួតពិនិត្យ។

**មាត្រា ១២.-**

ការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវអនុវត្តតាមបែបបទ និងលក្ខខណ្ឌ ដូចខាងក្រោម៖

- ត្រូវប្រើប្រាស់ឲ្យបានត្រឹមត្រូវ ចំគោលដៅស្របតាមលក្ខណៈបច្ចេកទេសក្នុងកម្រិតសុវត្ថិភាពខ្ពស់បំផុត
- ត្រូវរក្សាទុកឲ្យបានត្រឹមត្រូវនៅទីសុវត្ថិភាពដែលមិនអាចឲ្យក្មេង ឬជនដទៃផ្សេងទៀតយកទៅប្រើប្រាស់ ឬបង្កគ្រោះថ្នាក់ដល់អ្នកដទៃ
- ត្រូវរក្សាទុក ឬ បំផ្លាញកាកសំណល់ និងសំបកសម្ភារៈវេចខ្ចប់ឲ្យបានត្រឹមត្រូវ និងឲ្យស្របទៅតាមបទដ្ឋាន បច្ចេកទេសក្នុងកំរិតខ្ពស់បំផុត។
- ត្រូវធ្វើកំណត់ត្រាពីបរិមាណអាស៊ីដខ្លាំងគ្រប់ប្រភេទ ដែលបានប្រើប្រាស់ និងបរិមាណដែលនៅសល់ ។

## ជំពូកទី៣
## សមត្ថកិច្ចត្រួតពិនិត្យ

**មាត្រា ១៣.-**

ការត្រួតពិនិត្យលើការអនុវត្តបែបបទនិងលក្ខខណ្ឌសុវត្ថិភាពក្នុងការលក់ ការទិញ ការរក្សាទុក ការចែកចាយ ការដឹកជញ្ជូន ការវេចខ្ចប់ ការយកតាមខ្លួន និងការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១៤.-**

ក្រោយពេលអនុក្រឹត្យនេះ ចូលជាធរមានរយៈពេល ៦ខែ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលលក់ ទិញ រក្សាទុក ចែកចាយ ដឹកជញ្ជូន វេចខ្ចប់ យកតាមខ្លួន និងប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវអនុវត្តតាមបែបបទ និងលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី២ នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្ដីគោរពជូន**
**សម្ដេចនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

ស៊ុយ សែម

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ